**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ២៩៧៨ ព.ណ...ករ

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១ ខែតុលា ឆ្នាំ ២០២០

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ ឧកញ៉ា លោក លោកស្រីដែលជាម្ចាស់សហគ្រាស ផលិតករ សេវាករ ពាណិជ្ជករ និងសាធារណជនទូទៅដែលមានធុរកិច្ចទាក់ទងនឹងផ្នែកល្បែងកម្សាន្តសកល(Global Game)ឲ្យបានជ្រាបថា៖ មជ្ឈមណ្ឌលអាស៊ាន-កូរ៉េ (ASEAN-Korea Centre) នឹងរៀបចំកម្មវិធីតាំងពិព័រណ៍ល្បែងកម្សាន្តសកល "Global Game Exhibition-G-Star" ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៧-២០ ខែវិច្ឆិកា ឆ្នាំ២០២០ តាមរយៈប្រព័ន្ធអ៊ិនធឺណិត(Online)។

មជ្ឈមណ្ឌលអាស៊ាន-កូរ៉េ នឹងអញ្ជើញអ្នកជំនាញផ្នែកល្បែងកម្សាន្តសកលជា (Publishers and Developers) ចំនួន១០ក្រុមហ៊ុន ពីប្រទេសជាសមាជិកអាស៊ាននីមួយៗ ដើម្បីចូលរួមក្នុងកម្មវិធីតាំងពិព័រណ៍ល្បែងកម្សាន្តសកលនេះ។ កម្មវិធីនេះជាវេទិកាដ៏ល្អសម្រាប់ក្រុមហ៊ុនល្បែងកម្សាន្ត ដើម្បីណែនាំផលិតផលរបស់ខ្លួនទៅកាន់ទីផ្សារល្បែងកម្សាន្តសកល និងបង្កើនវត្តមានអាស៊ាននៅក្នុងទីផ្សារល្បែងកម្សាន្ត។

ដំណឹងនេះចាត់ទុកដូចជាការអញ្ជើញ ឧកញ៉ា លោក លោកស្រីដែលជាម្ចាស់សហគ្រាស ផលិតករ ពាណិជ្ជករ សេវាករ និងម្ចាស់ក្រុមហ៊ុនវិនិយោគ ដែលកំពុងធ្វើធុរកិច្ចលើវិស័យពាក់ព័ន្ធខាងលើហើយមានបំណងចូលរួមផ្សព្វផ្សាយ ពីផលិតផល ឬ សេវាកម្មរបស់ខ្លួន ឬមានគម្រោងស្វែងរកដៃគូពាណិជ្ជកម្មក្នុងព្រឹត្តិការណ៍ពិព័រណ៍នេះ សូមបំពេញបែបបទនិងចុះឈ្មោះតាមរយៈលោកស្រី Yeom Su-jin ទូរស័ព្ទលេខ +៨២-២-២២៨៧-១១៩៥ និងអ៊ីម៉ែល sjyeom@aseankorea.org និងចម្លងជូន bsokhen@gmail.com។

**សូមអរគុណ!**

KINGDOM OF CAMBODIA

Nation - Religion - King

Ministry of Commerce

N°2978.MOC.D./.EA

Phnom Penh, 1 October, 2020

**ANNOUNCEMENT**

The Ministry of Commerce of the Kingdom of Cambodia has the honor to inform all the traders and entrepreneurs that ASEAN Korea Center (AKC) will participate in ***Global Game Exhibition G-Star*** hosted by Korea Association of Game Industry ( K-Games )to be virtually held from November 17th-20th, 2020.

The AKC will invite ten game companies per each member state to participate in the online B2B meeting.The program is expected to enhance the global competitiveness of ASEAN game companies and to provide business opportunities for ASEAN and Korean game companies.

In this regard, the Ministry of Commerce would like to invite all interested entrepreneurs, producers, traders, service providers and investment companies of which their business activities are related to above-mentioned industry and wish to participate in the event to kindly contact Ms. Yeom Su-jin, via phone number: +82-2-2287-1195, email : sjyeom@aseankorea.org and CC to: bsokhen@gmail.com for registration.

THANK YOU!